វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៨ អនក្រ.បក/ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០០

# អនុក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទិ ១៩ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- តាមសំណើរបស់ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សំរេច:

ជំពូកទី ១: បទប្បញ្ញត្តិទូទៅ

មាត្រា ១

ត្រូវបានបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី សំរាប់ជំនួយការ ក្នុងប្រត្តិបត្តិការសកម្មភាពរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងវិស័យដីធ្លី ។ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានទីតាំងស្ថិតនៅទីស្តីការក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់។

## ជំពូកទី ១: បេសកម្ម និងសមាសភាព

មាត្រា ២

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានបេសកកម្មផ្តួចផ្តើមជំរុញដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តន៏គោលនយោបាយ និង កម្មវិធីការងារដីធ្លី ស្របតាមការតម្រង់ទិសរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

មាត្រា ៣

ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានមុខងារ និងភារកិច្ចដូចតទៅ :

១. ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងផែនការកម្មវិធីការងារ និង យុទ្ធសាស្ត្រសំរាប់ធ្វើឱ្យសំរេចគោលដៅទាំងឡាយនៃការរៀបចំ ការគ្រប់គ្រង និងការបែកចែកដីធ្លី ។

២. អនុវត្តសេចក្តីណែនាំដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់ឱ្យដំណើរការយុទ្ធសាស្ត្រ និងកម្មវិធីការងារដីធ្លី ។

៣. ចេញសេចក្តីសំរេច និង សេចក្តីណែនាំដល់ក្រសួង ស្ថាប័ន ខេត្ត ក្រុងក្នុងការដាក់ឱ្យដំណើរការកម្មវិធីការងារក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន។

៤. សំរបសំរួលសកម្មភាពនានារបស់ក្រសួង ស្ថាប័នទាំងឡាយដែលទាក់ទងទៅនឹងកម្មវិធីការងារដីធ្លី ។

៥. លើកសំណើគោលនយោបាយដីធ្លី ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ដើម្បីសុំការសំរេច ។

៦ លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងច្បាប់ លិខិតបទដ្ឋាន និង វិធានការទាំងឡាយដែលទាក់ទងនឹងកិច្ចដំណើរការងារដីធ្លី ។

៧. សំរបសំរួលមធ្យោបាយរបស់រដ្ឋ និងជំនួយអន្តរជាតិសំរាប់ប្រើប្រាស់ ក្នុងការងារដីធ្លី ។

៨. ដឹកនាំ និងគ្រប់គ្រងការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និង ប្រជាពលរដ្ឋ ទូទៅ ជាពិសេសអំពីការងារដីធ្លី ។

៩. ធ្វើរបាយការណ៍ជាប្រចាំជូន ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ អំពីលទ្ធផលនៃការងារដីធ្លី ។

មាត្រា ៤

ក្រុមប្រឹក្សាកំណែទំរង់ដីធ្លី មានសមាសភាពដូចតទៅ :

| | |
|---|---|
| - រដ្ឋមន្រ្តី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ប្រធាន |
| - រដ្ឋមន្រ្តី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| - រដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី | ជាសមាជិកអចិន្រ្តៃយ៍ |
| - រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងការពារជាតិ | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួង បរិស្ថាន | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងពតិមាន | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួង សាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងអតីយុទ្ធជន | ជាសមាជិក |
| - រដ្ឋលេខាធិការ នៃក្រសួងផែនការ | ជាសមាជិក |
| - អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្រ្តី | ជាសមាជិក |
| - អគ្គរដ្ឋលេខាធិការ នៃគណៈកម្មការវិនិយោគកម្ពុជា | ជាសមាជិក |

មាត្រា ៥

ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចដូចតទៅ :

- ទទួលខុសត្រូវ បំពេញមុខការទាំងឡាយរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដូចមានចែងក្នុងមាត្រាខាងលើ និង យកចិត្តទុកដាក់ធ្វើឱ្យដំណើរការការងារដីធ្លីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព
- អញ្ជើញសមាជិកចូលរួមប្រជុំ កំណត់របៀបវារៈ នៃការប្រជុំនានា របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ដឹកនាំការពិភាក្សា និងចេញសេចក្តីសំរេចនានា

- អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានសមត្ថភាពជំនាញមកចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- មានសិទ្ធិចុះហត្ថលេខាទ្វេភាគី និងពហុភាគីគ្រប់កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន និងគ្រប់កិច្ចសន្យា ឬ អត្ថបទគតិយុត្តដែលទាក់ទងទៅនឹងការងារដីធ្លី
- មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាគោលនយោបាយ ដីធ្លី ។

**មាត្រា ៦**

ប្រធានក្រុមប្រឹក្សាគោលនយោបាយ ដីធ្លី មានសិទ្ធិលើកសំណើតែងតាំងតាមករណីចាំបាច់ អ្នកជំនាញការជាតិ និង អន្តរជាតិ ហើយនិងឥស្សរជន ឬមន្ត្រីរាជកាជាន់ខ្ពស់ ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាលបច្ចេកទេស ជាទីប្រឹក្សាបច្ចេកទេស ដើម្បីសិក្សាវិភាគធ្វើទស្សនទាន ឬ ផែនការកម្មលើការងារដីធ្លី និងលើកសំណើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី នូវគំរោងការងារដីធ្លី ដែលត្រូវដាក់ឱ្យអនុវត្ត។

## ជំពូកទី ៣: អគ្គលេខាធិការដ្ឋាន

**មាត្រា ៧**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

អគ្គលេខាធិការមាន អគ្គលេខាធិការរង និងទីប្រឹក្សាជាជំនួយការ ។ អគ្គលេខាធិការរង និង ទីប្រឹក្សាត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើររបស់ អគ្គលេខាធិការ ដោយមានមតិយល់ព្រមពីប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ៨**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃ ក្រុមប្រឹក្សាគោលនយោបាយ ដីធ្លីត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

មាត្រា ៩

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ដើម្បីបំពេញការងាររបស់ខ្លួន

## ជំពូកទី៤: ប្រភពធនធាន

មាត្រា ១០

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានខ្ទង់ថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់។

**មាត្រា ១១**

ធនធាន និងថវិការបស់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានផ្គត់ផ្គង់ដោយ :

- វិភាគទាន នៃថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេស ឬ អង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៥: អវសានប្បញ្ញត្តិ

**មាត្រា១២**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យ នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៣**

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័ន និងសមាជិកទាំងអស់ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវទទួលបន្ទុករៀងៗ ខ្លួន អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។